មជ្ឈមណ្ឌលឯកសារកម្ពុជា

# សាលាក្តីខ្មែរក្រហម : យុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍នៅកម្ពុជា?

**បណ្ឌិត វេនឌី ឡែមបិន**

មជ្ឈមណ្ឌលសម្រាប់ការសិក្សាអំពីសន្តិភាពនិងជម្លោះនៃសកលវិទ្យាល័យស៊ីដនី

*“អំពើប្រល័យពូជសាសន៍ប្រៀបដូចជាភាពសាយភាយអាវុធនុយក្លេអ៊ែរ ដោយហេតុថា អ្នកនៅជាមួយវាអស់មួយជីវិត”* ដោយ រិទ្ធី ប៉ាន់

*“គ្មានយុត្តិធម៌ យើងនឹងមិនមានសន្តិភាពក្នុងចិត្ត”* ដោយ ឆាំង យុ

ការស្វែងរកការទទួលខុសត្រូវសម្រាប់របបខ្មែរក្រហមគឺជារឿងដ៏យូរប្រកបដោយការខកចិត្ត រួមជាមួយនឹងភាពអត់ធ្មត់ ដែលដឹកនាំដោយសហគមន៍អន្តរជាតិនិងអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ ដែលនៅទីបំផុតនឹងចេញជាផ្លែផ្កា ដូចដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) រៀបចំឡើងដើម្បីចាប់ផ្តើមធ្វើការចោទប្រកាន់ ។ ដោយសម្រេចបានសមិទ្ធិផលគួរឲ្យកត់សម្គាល់ អ្វីដែលមិនសូវច្បាស់ថាតើអង្គជុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចផ្តល់យុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍នៅកម្ពុជា និងបញ្ចប់វប្បធម៌និទណ្ឌភាពដែលជ្រួតជ្រាបនៅក្នុងសង្គមកម្ពុជាអស់រយៈពេល៣០ឆ្នាំមកហើយដែរឬអត់ ។ អត្ថបទនេះនឹងពិចារណាឧបសគ្គនិងភាពស្មុគស្មាញខាងនយោបាយទាំងឡាយក្នុងការស្វែងរកការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរបបខ្មែរក្រហម ហើយនឹងវាយតម្លៃកម្រិតដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទំនងជាអាចបំពេញបាននូវសេចក្តីត្រូវការនិងការរំពឹងគិតទុករបស់ប្រជាជនកម្ពុជាចំពោះយុត្តិធម៌ក្នុងទម្រង់ការពិតនិងការទទួលស្គាល់ ដែលអាចឆ្លើយតបនឹងសំណួរដែលសង្កត់ធ្ងន់ថាតើហេតុអ្វីបានជាឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើង ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងត្រូវបានវាយតម្លៃក្នុងលក្ខខណ្ឌសមត្ថភាពដែលមិនត្រឹមតែផ្តល់យុត្តិធម៌សម្រាប់អតីតកាលឡើយ ប៉ុន្តែថែមទាំងជំរុញឲ្យមានយុត្តិធម៌សម្រាប់ពេលអនាគតតាមរយៈនីតិរដ្ឋនិងការគោរពសិទ្ធិមនុស្ស ។ អត្ថបទនេះនឹងផ្តោតបន្ថែមទៀតទៅលើសំណួរដែលការសន្មត់បែបវប្បធម៌របស់យុត្តិធម៌តាមផ្លូវច្បាប់របស់ប្រទេសខាងលិចផ្តល់ដោយអង្គ

ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងស្នើសុំជាយោបល់សម្រាប់សេចក្តីត្រូវការនៃវិធីសាស្ត្រតាមជម្រើសដែលប្រហែលជាទទួលបានជោគជ័យក្នុងការជំរុញឲ្យមានសន្តិភាពនិងយុត្តិធម៌ក្នុងប្រទេសកម្ពុជា ។

## បរិបទប្រទេសកម្ពុជា

ប្រទេសកម្ពុជាធ្លាប់ជាជាតិមួយដ៏អស្ចារ្យដោយគ្របដណ្តប់មួយភាគធំក្នុងតំបន់អាស៊ីអាគ្នេយ៍រួមជាមួយវប្បធម៌ខ្មែរដាច់ដោយឡែករបស់ខ្លួនដែលទទួលឥទ្ធិពលពីសាសនាធំៗពីរបស់ឥណ្ឌា គឺសាសនាហិណ្ឌូនិងព្រះពុទ្ធសាសនា ។ បន្ទាប់ពីបានឡើងដល់កំពូលក្នុងរាជវង្សអង្គរ អាណាចក្រខ្មែរដ៏ល្បីល្បាញមានមានរយះពេលចាប់ពីសតវត្សរ៍ទី៧ដល់សតវត្សរ៍ទី១៣ បន្ទាប់ពីនោះអាណាចក្រខ្មែរចុះទន់ខ្សោយបន្តបន្ទាប់ដោយសារការលុកលុយពីប្រទេសសៀម (បច្ចុប្បន្នប្រទេសថៃ) និងប្រទេសវៀតណាមដែលជាប្រទេសជិតខាងរបស់ខ្លួន ។ នៅឆ្នាំ១៨៦៣ ប្រទេសកម្ពុជាបានស្ថិតក្រោមការគ្រប់គ្រងរបស់បារាំងនិងក្រោយមកបានស្ថិតក្រោមអាណានិគមរបស់បារាំងរហូតដល់ឆ្នាំ១៩៥៣ នៅពេលសម្តេចនរោត្តម សីហនុ ទាមទារបានឯករាជ្យជូនប្រទេស ។

បន្ទាប់ពីរយៈពេល១៧ឆ្នាំនៃសន្តិភាពក្នុងនាមជាប្រទេសឯករាជ្យ ប្រទេសកម្ពុជាបានធ្លាក់ក្នុងសង្គ្រាមវៀតណាម ។ នៅឆ្នាំ១៩៦៩ ទ័ពអាកាសសហរដ្ឋអាមេរិកបានចាប់ផ្តើមទម្លាក់គ្រាប់បែកយ៉ាងសម្ងាត់ទៅលើប្រទេសកម្ពុជា ដើម្បីបំបាត់មូលដ្ឋានកុម្មុយនីស្តវៀតណាម ហើយរដ្ឋាភិបាលលន់នល់ដែលប្រឆាំងនឹងវៀតណាមបានកាន់កាប់ប្រទេសកម្ពុជា (ដូរឈ្មោះប្រទេសទៅជាសាធារណៈរដ្ឋខ្មែរ) ។ សីហនុ ដែលឥឡូវនេះបាននិរទេសខ្លួនទៅក្រៅប្រទេស បានបង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរក្រហមដែលគាំទ្រដោយកុម្មុយនីស្ត និងបានបង្កើតឲ្យមានសង្គ្រាមស៊ីវិលជាមួយរដ្ឋាភិបាលលន់នល់ដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៧៥ សហរដ្ឋអាមេរិក បានដកថយពីប្រទេសវៀតណាម ទីក្រុងភ្នំពេញបានធ្លាក់ទៅក្នុងដៃខ្មែរក្រហម ហើយប្រជាជនកម្ពុជាបានធ្លាក់ទៅក្នុងរបបខ្មែរក្រហមរយៈពេល៣ឆ្នាំ ដែលដឹកនាំដោយ ប៉ុល ពត (របបកម្ពុជាប្រជាធិបតេយ្យ) ដែលក្រោមរបបនេះប្រជាជនពី១លានទៅ២លាននាក់បានស្លាប់ ។

នៅខែមករា ឆ្នាំ១៩៧៩ ទីក្រុងភ្នំពេញបានធ្លាក់ទៅក្នុងដៃវៀតណាម ខ្មែរក្រហមបានដកថយទៅកាន់ព្រំដែនថៃ ហើយប្រទេសកម្ពុជាបានដូរឈ្មោះ ទៅជាសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (ស.ប.ក) ។ សហគមន៍អន្តរជាតិបានថ្កោលទោសការលុកលុយរបស់វៀតណាម ហើយរបបប៉ុលពតនៅតែទទួលបានការទទួលស្គាល់ដោយអង្គការសហប្រជាជាតិថា ជារដ្ឋាភិបាលផ្លូវការរបស់ប្រទេស

កម្ពុជា ។ នៅឆ្នាំ១៩៨៩ រដ្ឋាភិបាលទីក្រុងភ្នំពេញដែលមាន ហ៊ុន សែន ជានាយករដ្ឋមន្ត្រី បានបោះបង់ចោលរបបកុម្មុយនីស្តនិងបានប្តូរឈ្មោះប្រទេសទៅជារដ្ឋកម្ពុជា ហើយវៀតណាមបានដកចេញពីកម្ពុជា ។ ការបោះឆ្នោតនៅខែឧសភា ឆ្នាំ១៩៩៣ ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអន្តរកាលរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) បង្កើតបានរដ្ឋាភិបាលចម្រុះជាមួយព្រះអង្គម្ចាស់ រណឫទ្ធិ (បុត្រារបស់ សីហនុ) និង ហ៊ុន សែន (មេដឹកនាំគណៈបក្សប្រជាជនកម្ពុជាដែលគាំទ្រដោយវៀតណាម) ជាសហនាយករដ្ឋមន្ត្រី ។ ទោះបីយ៉ាងណាក៏ដោយ បន្ទាប់ពីមានរដ្ឋប្រហារប្រឆាំងនឹង រណឫទ្ធិ ព្រមទាំងគូបដិបក្ខដទៃទៀតរបស់ខ្លួននៅឆ្នាំ ១៩៩៧ ហ៊ុន សែន បានប្រកាសខ្លួនជានាយករដ្ឋមន្ត្រីតែមួយគត់របស់ប្រទេសកម្ពុជា ។ គណៈបក្សប្រជាជនកម្ពុជារក្សាអំណាចបានចាប់តាំងពីពេលនោះមកដែលមាន ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ។

## រយៈពេល៣០ឆ្នាំនៃនិទណ្ឌភាព

បន្ទាប់ពីរបបប្រល័យពូជសាសន៍ ប៉ុល ពត មិនមានដំណើរការដាក់ឲ្យទទួលខុសត្រូវជាសាធារណៈតាមផ្លូវការដ៏មានប្រសិទ្ធិភាពនិងជាដុំកំភួនត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា ទោះបីជាការផ្តួចផ្តើមគំនិតមួយចំនួនបានស្នើឡើងដោយសហគមន៍អន្តរជាតិនិងរដ្ឋាភិបាលកម្ពុជា ។ មិនមានសកម្មភាពថ្កោលទោសជាអន្តរជាតិផ្លូវការឬការចោទប្រកាន់ណាមួយដែរ ។ តុលាការប្រជាជនបដិវត្តន៍សម្រាប់មេដឹកនាំខ្មែរក្រហម ៖ ប៉ុល ពត និង អៀង សារី ដែលបានរៀបចំឡើងនៅខែសីហា ឆ្នាំ១៩៧៩ នៅទីក្រុងភ្នំពេញបានកាត់ទោសប្រហារជីវិតដោយកំបាំងមុខចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប៉ុន្តែការកាត់ទោសនេះមិនត្រូវបានទទួលស្គាល់ជាអន្តរជាតិដោយសារតែផ្ទុយទៅនឹងដំណើរការសមស្រប និងការដាច់ឆ្ងាយខាងការទូតរបស់របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ហើយការដាក់ទោសប្រហារជីវិតមិនត្រូវបានធ្វើឡើងទេ ។ យោងតាម ហ៊ែម៉រ និង អូរ្យ (ឆ្នាំ២០០៥ ទំព័រ២៦) ការប្រែត្រឡប់តុលាការទៅជាឧបករណ៍ឃោសនារបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានបង្កើតឲ្យមានយុត្តិធម៌ក្នុងរូបភាពនយោបាយ ។

ជំហរសហគមន៍អន្តរជាតិត្រូវបានបង្អាក់ដោយដែនកំណត់សង្គ្រាមត្រជាក់ អទិភាពនយោបាយ និងការគោរពបូរណភាពដែនដី ពីការថ្កោលទោសអំពើឃោរឃៅក្នុងរបបប៉ុលពត ។ នៅពេលដែលសង្គ្រាមត្រជាក់បានបញ្ចប់ សហគមន៍អន្តរជាតិនៅតែកម្រិតដោយកេរតំណែលសម្ព័ន្ធភាពនយោបាយ ភូមិសាស្ត្រសង្គ្រាមត្រជាក់ ក៏ដូចជាការភ័យខ្លាចថា ពួកគេប្រហែលជាត្រូវទទួលខុសត្រូវចំពោះតួនាទីរបស់ខ្លួនដែលបានគាំទ្រខ្មែរក្រហម ។ អង្គការសហប្រជាជាតិបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងសន្តិភាពក្នុងប្រទេសកម្ពុជា ប៉ុន្តែបញ្ហាយុត្តិធម៌និងការផ្សះផ្សាជាតិមិនត្រូវបានដោះស្រាយនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅខែតុលា ឆ្នាំ១៩៩១ឡើយ ។ កិច្ចព្រមព្រៀង

ចុងក្រោយមិនបានរារាំងអតីតមន្ត្រីខ្មែរក្រហមដែលពាក់ព័ន្ធជាមួយអំពើប្រល័យពូជសាសន៍កាន់តំណែងនៅពេលអនាគតឡើយ ។ ហ៊ែម័រ និង អួរូ (ឆ្នាំ២០០៥) ចាត់ទុកការបរាជ័យនេះទៅក្នុងការស្វែងរកយុត្តិធម៌សម្រាប់របបខ្មែរក្រហមក្នុងអំឡុងពេលទាំងពីរនេះចំពោះ "នយោបាយមនោគមវិជ្ជា" (ឆ្នាំ១៩៧៥-៨៩) និង "នយោបាយស្ថាបនាឡើងវិញ" (ឆ្នាំ១៩៨៩-១៩៩៦) ។ ដូចដែលបានចង្អុលបង្ហាញដោយ អ៊ិចឆេសាន់ គឺ"បញ្ហាយុត្តិធម៌អន្តរកាលនិងការទទួលខុសត្រូវចំពោះអំពើរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិតែងតែមានលក្ខណៈនយោបាយតឹងតែង" ។

ខណៈពេលនេះរបបខ្មែរក្រហមអាចរក្សាតំបន់កាន់កាប់នៅក្នុងទីប្រជុំជនមួយចំនួនដូចជាប៉ៃលិននៅជិតព្រំដែនថៃ ។ ពួកគេបានបន្តសកម្មភាពទ័ពព្រៃរបស់ខ្លួនជាមួយនិរទណ្ឌភាពរយៈពេល ២០ឆ្នាំរហូតដល់អង្គការចាត់តាំងនេះត្រូវបានបំបែកជាផ្លូវការនៅឆ្នាំ១៩៩៨ បន្ទាប់ពីមរណៈភាពរបស់ប៉ុល ពត និងការចុះចូលរបស់អតីតមេដឹកនាំខ្មែរក្រហមពីររូប គឺ ខៀវ សំផន និង នួន ជា ។ អៀង សារី បានចុះចូលបន្ទាប់ពីគាត់ត្រូវបានផ្តល់ការលើកលែងទោសនៅឆ្នាំ១៩៩៦ ខណៈពេលដែលអតីតមេដឹកនាំខ្មែរក្រហមពីរូបផ្សេងទៀត គឺ តាម៉ុក និង ឌុច ត្រូវបានចាប់ខ្លួនដោយរដ្ឋាភិបាលកម្ពុជានៅខែមីនានិងខែឧសភា ឆ្នាំ១៩៩៩ ។ អ្នកទាំងពីរនេះប្រឈមមុខនឹងការចោទប្រកាន់ពីបទក្បត់ជាតិការធ្វើទារុណកម្ម ការសម្លាប់ និងអំពើប្រល័យពូជសាសន៍ ព្រមទាំងបំពានច្បាប់ដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ។ តាម៉ុក ស្លាប់នៅឆ្នាំ២០០៦ ប៉ុន្តែ ខៀវ សំផន, នួន ជា, អៀង សារិ និង ឌុច ព្រមទាំង អៀង ធីរិទ្ធី នៅរស់រានមានជីវិតដើម្បីទទួលការចោទប្រកាន់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ដំណើរយឺតៗទៅរកការដាក់ឲ្យទទួលខុសត្រូវ

ការអនុម័តច្បាប់ស្តីពីយុត្តិធម៌ទៅលើអំពើប្រល័យពូជសាសន៍នៅកម្ពុជានៅក្នុងសហរដ្ឋអាមេរិកនៅខែមេសា ឆ្នាំ១៩៩៤ និងការអនុម័តច្បាប់ដាក់ឲ្យខ្មែរក្រហមនៅក្រៅច្បាប់របស់រដ្ឋាភិបាលកម្ពុជានៅខែកក្កដា ឆ្នាំ១៩៩៤ គឺជាចំណុចរបត់ក្នុងការធ្វើដំណើរទៅរកការដាក់ឲ្យទទួលខុសត្រូវ ។ នៅដើមឆ្នាំ១៩៩៧ អង្គការសហប្រជាជាតិបាន ចាប់ផ្តើមកិច្ចខិតខំប្រឹងប្រែងបង្កើតសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ហើយនៅខែមិថុនា សហនាយករដ្ឋមន្ត្រីគឺ ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ និង ហ៊ុន សែន បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីបង្កើតសាលាក្តីជាផ្លូវការ ។ ទោះបីជាយ៉ាងណា កិច្ចខិតខំប្រឹងប្រែងទាំងនេះជួបប្រទះការលំបាកក្នុងការព្យាយាមស្វែងរកឆន្ទៈរបស់ប្រទេសក្នុងការបង្កើតឡើងដោយស្របច្បាប់ និងដើម្បីកាត់សេចក្តី ប៉ុល ពត ។ ជាបន្តបន្ទាប់ របាយការណ៍របស់ក្រុមជំនាញអង្គការសហប្រជាជាតិដែលបានចេញផ្សាយនៅខែវិច្ឆិការ ឆ្នាំ១៩៩៨ បានឲ្យយោបល់ដើម្បីបង្កើតសាលាក្តីអន្តរជាតិពិសេស ហើយនៅខែមីនា ឆ្នាំ១៩៩៩

អគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជូនសំណើសុំឲ្យមានការបង្កើតសាលាក្តីអន្តរជាតិទៅកាន់ក្រុមប្រឹក្សាអង្គការសហប្រជាជាតិនិងមហាសន្និបាតអង្គការសហប្រជាជាតិ ។

ទោះបីយ៉ាងណាក៏ដោយ ការបង្កើតសាលាក្តីត្រូវបានពន្យារពេលដោយសារភាពអសមត្ថភាពរបស់អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាក្នុងការយល់ស្របទៅលើការគាត់តែងនិងមុខងារដំណើរការរបស់សាលាក្តីដែលបានស្នើឡើង ។ នៅក្នុងដំណាក់មួយនោះ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានច្រានចោលសាលាក្តីអន្តរជាតិ ដោយចាត់ទុកថាជាការគំរាមកំហែងដល់ការផ្សះផ្សាជាតិរបស់ប្រទេស ហើយបានចង្អុលបង្ហាញនូវការពេញចិត្តរបស់គាត់ចំពោះតុលាការជាតិ ដែលមានជំនួយការផ្លូវច្បាប់ពីអន្តរជាតិ ។ ប្រជាជនកម្ពុជាមួយចំនួនរួមទាំងអតីតខ្មែរក្រហមបានសម្តែងការភ័យខ្លាចថាសាលាក្តីអាចបង្កឲ្យមាន អំពើហិង្សាបន្ថែមទៀត ។ អ្នកផ្សេងទៀតបានច្រានចោលការគំរាមកំហែងនេះដោយចាត់ទុកថាជាការឃោសនាដែលធ្វើឡើងដោយអតីតខ្មែរក្រហមដើម្បីការពារខ្លួនពីការចោទប្រកាន់ដែលអាចកើតឡើង ។

ការសម្រេចបានក្នុងការចរចាបានកើតឡើងនៅខែមេសា ឆ្នាំ២០០១ នៅពេលដែលព្រឹទ្ធសភាសហរដ្ឋអាមេរិក ចន ខែរី ជួយបញ្ចុះបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងឲ្យសាលាក្តីរួមមួយសម្រាប់កម្ពុជានិងអង្គការសហប្រជាជាតិ ដែលរួមមានទាំងចៅក្រមនិងសហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ សេចក្តីព្រាងអនុស្សរណៈយោគយល់ត្រូវបានដាក់ជូនដោយអង្គការសហប្រជាជាតិដល់រដ្ឋាភិបាលកម្ពុជានៅខែកក្កដា ឆ្នាំ២០០០ ប៉ុន្តែច្បាប់ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជានៅខែមករា ឆ្នាំ២០០១ ខកខានមិនបានបំពេញតម្រូវការនូវលក្ខខណ្ឌសំខាន់ៗមួយចំនួនរបស់អនុស្សរណៈយោគយល់ ។ ជាបន្តបន្ទាប់មកទៀត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ អង្គការសហប្រជាជាតិបានប្រកាសថា ខ្លួនបានបោះបង់ការចរចាជាមួយរដ្ឋាភិបាលកម្ពុជាដោយសារ «ដូចដែលបានមើលឃើញថាតុលាការកម្ពុជាបច្ចុប្បន្នមិនអាចធានាបាននូវឯករាជ្យភាព ភាពមិនលម្អៀង និងកត្តាសត្យានុម័ត ដែលតម្រូវដោយអង្គការសហប្រជាជាតិដើម្បីសហការជាមួយសាលាក្តី» ។ អង្គការសហប្រជាជាតិនិងប្រទេសអន្តរជាតិជាច្រើនបានសម្តែងការព្រួយបារម្ភថា «ប្រព័ន្ធយុត្តិធម៌កម្ពុជាដែលមានលក្ខណៈពុករលួយនិងទន់ខ្សោយមិនអាចមានលទ្ធភាពផ្ទាល់ខ្លួនដើម្បីបង្កើតឲ្យមានតុលាការនិងសាលក្រមយុត្តិធម៌» ។

ការបញ្ចុះបញ្ចូលយ៉ាងតានតឹងរបស់រដ្ឋាភិបាលអាមេរិកនិងភាគីដទៃទៀតបានដាក់សម្ពាធទៅលើអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ដើម្បីដោះស្រាយនូវភាពខុសគ្នានិងការចរចា ដែលបានបន្តនៅខែមករា ឆ្នាំ២០០៣ ។ នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើសេចក្តីព្រាងកិច្ចព្រមព្រៀង ប៉ុន្តែកិច្ចការនេះបានចំណាយពេល

ពីរឆ្នាំទៀតដើម្បីផ្តល់ឲ្យនូវការរៀបចំដើម្បីចរចា និងព្រមព្រៀងទៅលើទម្រង់ចុងក្រោយរបស់សាលាក្តីកូនកាត់នេះ ។ នៅទីបំផុត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងនៅខែវិច្ឆិកា ឆ្នាំ២០០៥ និងនៅត្រឹមខែឧសភា ឆ្នាំ២០០៦ ចៅក្រមនិងព្រះរាជអាជ្ញាត្រូវបានតែងតាំង ។ សវនាការត្រូវបានរំពឹងថានឹងចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ២០០៧ ប៉ុន្តែនៅត្រឹមឆ្នាំ២០០៨ មានតែសវនាការដំបូងប៉ុណ្ណោះត្រូវបានចាប់ផ្តើម ។

## ដែនកំណត់យុត្តិធម៌

អង្គជំនុំជម្រះវិសាមញ្ញគឺជាសាលាក្តីមួយក្នុងចំណោមសាលាក្តីកូនកាត់មួយចំនួនតូចដែលបានបង្កើតឡើងដោយអង្គការសហប្រជាជាតិរួមជាមួយរដ្ឋាភិបាលរបស់ប្រទេស ។ ដោយហេតុថា ការពន្យារពេលពិសេសៗមួយចំនួននៅក្នុងការបង្កើតសាលាក្តី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាសាលាក្តីដែលគាំទ្រដោយអន្តរជាតិតែមួយគត់ ដើម្បីចោទប្រកាន់បទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងក្នុងអំឡុងសង្គ្រាមត្រជាក់ ហើយវាគឺជាសាលាក្តីតែមួយគត់ដែលចាប់ផ្តើមដំណើរការតាំងពីការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។ សាលាក្តីនេះប្រឈមមុខនឹងឧបសគ្គមួយចំនួនក្នុងការទទួលបានមូលនិធិគ្រប់គ្រាន់ ដោយបានជម្នះការពន្យារពេលជាច្រើនដងតាំងពីចាប់ដំណើរការ និងប្រតិបត្តិការបន្តបន្ទាប់ ដោយរក្សានូវស្តង់ដារយុត្តិធម៌និងចោទប្រកាន់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងជាង៣០ឆ្នាំកន្លងមក ។

ទោះបីជាសាលាក្តីអាចបំពេញតម្រូវការប្រតិបត្តិការនិងផ្លូវច្បាប់ សំណួរជាច្រើននៅតែចោទសួរអំពីសមត្ថភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីបំពេញសេចក្តីត្រូវការឲ្យមានការទទួលខុសត្រូវនិងការប៉ងប្រាថ្នារបស់ប្រជាជនកម្ពុជាឲ្យមានការពិតនិងយុត្តិធម៌ ហើយសំខាន់ជាងនេះទៀត គឺបំណងប្រាថ្នាយល់ដឹងថាហេតុអ្វីបានជាឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយកម្ពុជាប្រឆាំងនឹងប្រជាជនរបស់ខ្លួន ។ យុត្តាធិការលើកាលបរិច្ឆេទរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានន័យថា មិនអាចចោទប្រកាន់ឧក្រិដ្ឋកម្មដែលបានធ្វើឡើងដោយរដ្ឋាភិបាលលន់នល់ដែលដឹកនាំបន្តដោយរបបប៉ុលពត ឬមិនអាចដោះស្រាយឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងតួនាទីរបស់រដ្ឋាភិបាលបរទេសដែលជួយនិងជំរុញលើកទឹកចិត្តរបបខ្មែរក្រហម ឬមិនអាចដោះស្រាយឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយ ហ៊ុន សែន និងរដ្ឋាភិបាលដែលបានរៀបចំឡើងដោយវៀតណាម ។ សមត្ថភាពរបស់ខ្លួនដើម្បីបញ្ចប់វប្បធម៌និទណ្ឌភាពដែលនៅតែរាលដាលនៅក្នុងប្រទេសកម្ពុជាត្រូវបានចាត់ទុកថាមានតែមួយចំណែកប៉ុណ្ណោះ ។ យុត្តាធិការផ្ទាល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានកម្រិតក្នុងការនាំយក «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភបំពានធ្ងន់ធ្ងរ» ទៅរកយុត្តិធម៌ ។ យុត្តាធិការនេះ

មិនអាចកាត់សេចក្តីមេដឹកនាំខ្មែរក្រហមទាំងឡាយណាដែលបានស្លាប់ រួមមាន ប៉ុល ពត និង តាម៉ុក ហើយអាចកាត់សេចក្តីតែមេដឹកនាំខ្មែរក្រហមសំខាន់ៗមួយក្តាប់តូចដែលនៅរស់ប៉ុណ្ណោះ ។ មនុស្សមួយចំនួនឲ្យយោបល់ផ្សេងថា ការយកធនធានបន្ថែមទៅប្រើប្រាស់ដើម្បីកាត់បន្ថយភាពក្រីក្រប្រសើរជាងបង្កើតសាលាក្តីដែលចំណាយលុយច្រើន ហើយនឹងកាត់សេចក្តីតែមនុស្សពីរបីនាក់ ។ ប្រធានអង្គការសិទ្ធិមនុស្សលីកាដូ ហ្កិច ហ្កាឡាប្រូ សួរសំណួរថាតើសាលាក្តីនេះអាច "នាំយកយុត្តិធម៌ជូនប្រជាជនកម្ពុជានិងអាចប្រយុទ្ធប្រឆាំងនឹងវប្បធម៌និទណ្ឌភាពបានដែរឬអត់? ឬ ថាតើសាលាក្តីនេះគ្រាន់តែជាសវនាការបង្ហាញឡើងដល់សហគមន៍អន្តរជាតិ ជាពិសេសដើម្បីធ្វើឲ្យម្ចាស់ជំនួយស្ងប់ចិត្ត?

វប្បធម៌និទណ្ឌភាពដែលមានឥទ្ធិពលនៅប្រទេសកម្ពុជាប្រហែលខ្លាំងជាងការបរាជ័យដើម្បីចោទប្រកាន់អតីតមេដឹកនាំខ្មែរក្រហម ដែលវប្បធម៌និទណ្ឌភាពនេះប្រហែលជាបន្តឲ្យមានកង្វះខាតការគោរពនីតិរដ្ឋនៅក្នុងប្រទេសដែលនៅតែប្រតិបត្តិតាមប្រព័ន្ធទ្រទ្រង់បែបនយោបាយ នៅពេលដែលអំណាចសំខាន់ជាងច្បាប់ ។ អង្គជំនុំជម្រះវិសាមញ្ញអាចកសាងសមត្ថភាពយុត្តិធម៌នៅប្រទេសកម្ពុជា ប៉ុន្តែថាតើមានប្រសិទ្ធិភាពយ៉ាងណានឹងអាស្រ័យលើសមត្ថភាពក្នុងការបណ្តុះបណ្តាលនិងបំពាក់ឲ្យកម្ពុជាដើម្បីបំលែងវប្បធម៌និទណ្ឌភាពឲ្យទៅជាសង្គមមួយដែលមានការគោរពនីតិរដ្ឋ ។ អ្វីដែលត្រូវការសម្រាប់បំលែងសង្គមគឺការកសាងអត្តសញ្ញាណជាតិថ្មីមួយ ដែលបដិសេធចោលនូវការលើកឡើងពីអតីតកាល និងឆ្លុះបញ្ចាំងតម្លៃនៃភាពមិនលម្អៀង គឺភាពស្របច្បាប់និងយុត្តិធម៌ ។ តម្លៃរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាអង្គប្រជុំមួយសម្រាប់បង្កើតអត្តសញ្ញាណខ្មែរ នឹងអាចធ្វើឲ្យប្រសើរឡើងដោយស្របតាមសវនាការផ្លូវច្បាប់ រួមមានយុទ្ធនាការសម្រាប់ការអប់រំជាសាធារណៈ ការពិភាក្សាតាមសហគមន៍ និងការផ្សះផ្សា ។

អង្គការសិទ្ធិមនុស្សនិងអង្គការក្រៅរដ្ឋាភិបាលដទៃទៀតកំពុងធ្វើការដើម្បីធានាឲ្យបានថាប្រជាជនកម្ពុជាអាចយល់ដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលការកម្ពុជា និងលើកឡើងនូវបញ្ហាដែលពាក់ព័ន្ធ ។ ឧទាហរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តកម្មវិធីផ្សព្វផ្សាយដល់សហគមន៍ ដោយបានអញ្ជើញអ្នកភូមិ៥០០០នាក់មកទីក្រុងភ្នំពេញ ដើម្បីមកធ្វើទស្សនកិច្ចសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតជើងឯក និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលអ្នកភូមិទាំងអស់អាចសួរសំណួរអំពីសវនាការដែលនឹងប្រព្រឹត្តឡើងនៅពេលខាងមុខ ។ គម្រោងនេះគឺថាអ្នកភូមិទាំងអស់នឹងត្រឡប់មកភ្នំពេញដើម្បីចូលរួមសវនាការរយៈពេល១សប្តាហ៍ ហើយដែលបន្ទាប់មកអ្នកភូមិនឹងរៀបចំការប្រជុំជាសាធារណៈស្តីពីអង្គជំនុំជម្រះវិសាមញ្ញនៅពេលដែលអ្នកភូមិត្រឡប់ទៅភូមិរបស់ខ្លួន ។ គម្រោងនេះហាក់ដូចជាបង្ហាញឲ្យឃើញអំពីភាពប្រសើរដ៏គួរឲ្យកត់សម្គាល់អំពីកិច្ចខិតខំប្រឹងប្រែងរបស់

កម្មវិធីផ្សព្វផ្សាយពាក់ព័ន្ធនឹងសាលាក្តីមុនៗដែលអ្នកនិពន្ធរូបនេះសង្កេតឃើញនៅក្នុងប្រទេសអ៊ីសទីម័រ ប្រទេសវ៉ាន់ដារ និងប្រទេសសេរ៉ាឡេអូន ។

យោងតាម ម៉ាឃែរ (ឆ្នាំ២០០៥ ទំព័រ១៩២-១៩៣) ប្រជាជនកម្ពុជាមួយចំនួនបោះបង់ចោលការដាក់ទណ្ឌកម្ម ហើយ "សព្វថ្ងៃប្រជាជនកម្ពុជាស្វះស្វែងរកការទទួលស្គាល់" ។ ទោះបីយ៉ាងណាក៏ដោយ ជំនឿទៅលើអង្គជំនុំជម្រះវិសាមញ្ញដើម្បីផ្តល់ការពិតនិងការទទួលស្គាល់ដោយអតីតខ្មែរក្រហមទំនងជាខុសកន្លែង ។ មិនមានសញ្ញាណណាមួយដែលអតីតមេដឹកនាំខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញ នឹងចៀសចេញពីការអនុវត្តសម្រាប់ការការពារសកម្មភាពមុនៗរបស់ខ្លួនថាជាជាការការពារប្រយោជន៍ឲ្យប្រជាជនកម្ពុជាឡើយ ។ ខៀវ សំផន នៅក្នុងលិខិតចំហកាលពីខែធ្នូ ឆ្នាំ២០០៣ សារភាពថាមាន "ការសម្លាប់ធ្វើឡើងជាប្រព័ន្ធ" ប៉ុន្តែនៅក្នុងដែលសៀវភៅចេញផ្សាយក្នុងឆ្នាំ២០០៤ គាត់បានអះអាងថា គាត់មិនបានដឹងអំពីគុកទួលស្លែងនិងគ្មានអំណាចដើម្បីបញ្ឈប់អំពើឃោរឃៅឡើយ ។ នួន ជា មិនមានវិប្បដិសារីចំពោះអតីតកាលដោយបានសារភាពថារបបខ្មែរក្រហមមានកំហុសខ្លះ ហើយបន្ទោសវៀតណាមដែលបង្កឲ្យមានរបបវាលពិឃាត ។ មេដឹកនាំទាំងពីរនេះចាត់ទុកខ្លួនជាអ្នកស្នេហាជាតិ ។ មេដឹកនាំទាំងនេះទម្លាក់កំហុសលើប៉ុល ពត ។

ទោះបីជាអតីតមេដឹកនាំខ្មែរក្រហមទាំងនេះបន្តបដិសេធកំហុសរបស់ខ្លួន ការរកឃើញរបស់អង្គជំនុំជម្រះវិសាមញ្ញទៅលើបុគ្គលដែលមានទោសអាចតទល់ដ៏រឹងមាំចំពោះការបដិសេធនិងទណ្ឌកម្មដែលបានកំណត់ អាចបំពេញបានចំពោះការស្នើសុំឲ្យមានយុត្តិធម៌តាមផ្លូវតុលាការ ។ សក្តានុពលជានិមិត្តរូបរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចបន្ទាបនៅក្នុងសំណើនេះឡើយ ។ ដូចដែលបានរៀបរាប់ដោយអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ដែលខ្ញុំបានសម្ភាសនៅទីក្រុងភ្នំពេញនៅខែតុលា ឆ្នាំ១៩៩៩ ថា "យើងត្រូវតែដាក់ទណ្ឌកម្ម[អតីតខ្មែរក្រហម] ដែលជាការទទួលខុសត្រូវរបស់ជាតិ ជាករណីធំបំផុតរបស់និទណ្ឌភាពនៅក្នុងពិភពលោក និងជាមាតារបស់និទណ្ឌភាពផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា" ។

ខណៈពេលដែលប្រជាជនកម្ពុជាភាគច្រើនបានបង្ហាញការប៉ងប្រាថ្នារបស់ខ្លួនឲ្យមានសាលាក្តីបែបនេះ ប្រជាជនកម្ពុជាផ្សេងទៀតបានបង្ហាញយោបល់ប្រឆាំងនឹងការដាក់កម្រិតឲ្យមានយុត្តិធម៌តាមផ្លូវច្បាប់បែបលោកខាងលិចដែលខុសប្លែកពីវប្បធម៌ខ្មែរ ។ យោងតាម ហែរីស (ឆ្នាំ២០០៥ ទំព័រ៨០) ការដាក់កម្រិតឲ្យមានប្រព័ន្ធអន្តរជាតិនិងទម្លាប់យុត្តិធម៌ជាសកលបែបនេះ "ប្រហែលរៀបចំរួចរាល់ដោយអង្គភាពមួយចំនួនរបស់សង្គមខ្មែរ [សម្រាប់អ្នកដែលជាជនជាតិខ្មែរជាពុទ្ធសាសនិក] ដូចជាការបញ្ឈរក់ពីការប្រមាថដល់ទំនៀមទម្លាប់របស់ខ្លួន" ។ ប្រជាជនកម្ពុជាមួយចំនួនឆ្លើយតប

ដោយបង្ហាញពីបំណងប្រាថ្នាឲ្យមាននិតិសាស្ត្របែបខ្មែរដើម្បីតទល់នឹងឥទ្ធិពលពីខាងក្រៅ ដែលបានក្បត់និងធ្វេសប្រហែសនូវតម្រូវការនិងសិទ្ធិរបស់ប្រជាជនកម្ពុជា ។ ប្រជាជនកម្ពុជាមួយចំនួនទាត់ចោលការផ្តួចផ្តើមតាមបែបទំនើបនេះ ដែលផ្តល់បុព្វសិទ្ធិដល់និតិសាស្ត្រនីតិរដ្ឋរបស់លោកខាងលិច ក្នុងការផ្តល់ទន្ន័ករណ៍ចំពោះសេចក្តីត្រូវការដើម្បីបង្ហាញឲ្យឃើញឡើងវិញនូវអត្តសញ្ញាណខ្មែរដែលពោរពេញទៅដោយសេចក្តីទុកចិត្តជាជាងការភ័យខ្លាចការលុកលុយពីខាងក្រៅ ។ ផ្ទុយមកវិញ ប៉ូកែមណើ (ឆ្នាំ២០០៥ ទំព័រ៣៥៨) ឲ្យយោបល់ផ្សេងថា ការទទូចសុំឲ្យមានស្តង់ដារអន្តរជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារបស់ប្រជាជនកម្ពុជាដែលខុសឆ្ងាយពីភាពខុសគ្នាបែបវប្បធម៌ គឺជាការឆ្លើយតបជាធម្មជាតិដើម្បីទទូចសុំឲ្យមានការពិចារណាសំខាន់លើការឈឺចាប់របស់ខ្លួនដូចប្រជាជនរ៉្វាន់ដានិងបូស្នៀ ដែលអាចទទួលបានស្តង់ដារច្បាប់ជាអន្តរជាតិពីសាលាក្តីអន្តរជាតិ ។

ដើម្បីបំពេញសង្គមកម្ពុជា ទស្សនៈវិស័យយុត្តិធម៌សង្គមទាមទារឲ្យមានជាជាងទស្សនៈវិស័យដែលផ្តល់ឲ្យដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទស្សនៈវិស័យមួយដែលរួមមានធាតុផ្សំយុត្តិធម៌បែបស្តាបនា សេដ្ឋកិច្ចសង្គម នយោបាយ និងចិត្តសាស្ត្រ បន្ថែមទៅនឹងយុត្តិធម៌តាមផ្លូវតុលាការ ។ ប៉ុន្តែខ្ញុំយល់ឃើញផ្សេងចំពោះគំនិតបង្កើតគណៈកម្មាការស្វែងរកការពិតដែលអាចដោះស្រាយបានច្រើនចំពោះតម្រូវការយុត្តិធម៌ទាំងនេះ ត្រូវបានច្រានចោលដោយប្រជាជនកម្ពុជាដោយហេតុផលមិនត្រឹមត្រូវមួយចំនួន ។ ដោយពិចារណាទៅលើតែគំរូគណៈកម្មាការស្វែងរកការពិតនិងផ្សះផ្សារបស់ប្រទេសអាហ្វ្រិកខាងត្បូង ប្រជាជនកម្ពុជាមានទស្សនៈតិចតួចនូវអ្វីដែលអាចធ្វើទៅបាន ។ ប្រជាជនកម្ពុជាសន្មត់ថា គណៈកម្មាការស្វែងរកការពិតមិនអាចដំណើរការបាននៅក្នុងប្រទេសកម្ពុជាដោយសារលក្ខខណ្ឌមួយចំនួនមិនត្រូវគ្នាជាមួយប្រទេសអាហ្វ្រិកខាងត្បូងដែលជាប្រទេសកាន់សាសនាគ្រឹស្ត និងមានការដឹកនាំបែបសាសនាខ្លាំង ដែលប្រឈមមុខនឹងអន្តរកាលពីរបបជិះជាន់ជាជាងសង្គ្រាមស៊ីវិលឬអំពើប្រល័យពូជសាសន៍ ។ គណៈកម្មការស្វែងរកការពិតនៅប្រទេសសេរ៉ាឡេអូនដោះស្រាយជាមួយឧក្រិដ្ឋកម្មធំរួម ដោយមិនបានរួមបញ្ចូលបញ្ញត្តិលើកលែងទោស ហើយបានកំពុងប្រតិបត្តិការនៅក្នុងសង្គមដែលគ្របដណ្តប់ដោយជនមុស្លីមព្រមទាំងអ្នកកាន់សាសនាគ្រឹស្តភាគច្រើន ។ គណៈកម្មការស្វែងរកការពិតនៅប្រទេសអ៊ីស្ទីម័រពាក់ព័ន្ធជាមួយសហគមន៍ក្នុងស្រុកនិងរួមបញ្ចូលដំណើរការផ្សះផ្សាបែបទំនៀមទម្លាប់ ហើយខណៈពេលដែលប្រទេសអ៊ីស្ទីម័រមានអ្នកដឹកនាំកាន់សាសនាគ្រឹស្តខ្លាំង មេដឹកនាំរូបនេះមិនបានដើរតួនាទីសំខាន់នៅក្នុងគណៈកម្មការស្វែងរកការពិតឡើយ ។

យោងតាមទស្សនៈវិស័យស្តីពីយុត្តិធម៌របស់ព្រះពុទ្ធ ទស្សនៈនេះ«ពាក់ព័ន្ធនឹងការ «មិនប្រព្រឹត្ត» អំពើឧក្រិដ្ឋកម្មដែលសណ្តាប់ធ្នាប់អាចត្រូវបានស្តារឡើងវិញ» ហើយគោលដៅបង្កើតឲ្យមានភាពសុខដុមរមនារវាងភាគីទាំងអស់ជាជាងភាពស្របគ្នាតាមគោលការណ៍ច្បាប់អរូបី ។ ទស្សនៈវិស័យ

ព្រះពុទ្ធស្របជាមួយគំនិតឲ្យមានយុត្តិធម៌បែបស្តារឡើងវិញ ដែលអាចរកឃើញតាមរយៈគណៈកម្មការស្វែងរកការពិតប្អូតាមរយៈយន្តការសមស្របបែបវប្បធម៌ផ្សេងទៀត ។ នាយកប្រតិបត្តិនៃវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ បណ្ឌិត ឡាវ មុងហៃ គាំទ្រការផ្សះផ្សាជាតិ (ជាជាងសាលាក្តី) ដែលស្របតាមទស្សនៈវិជ្ជាព្រះពុទ្ធ ហើយស្នើឲ្យមានការសារភាពកំហុសជាសាធារណៈរួមមួយ និងសំណើសុំឲ្យមានការលើកលែងទោសពីសំណាក់ព្រះមហាក្សត្រ ។ ប៉េរីស គាំទ្រឲ្យមានអំពើប្រកបដោយសច្ចៈធម៌ពាក់ព័ន្ធនឹងការទទួលស្គាល់ពិតនូវកំហុសប្អូគុណធម៌សីលធម៌ ដែលលាក់កំបាំងដោយអំណាចសម្រាប់ព្រះពុទ្ធសាសនាយានតូច ។

## សេចក្តីបញ្ចប់

បន្ទាប់ពីរយៈពេល៣០ឆ្នាំ នៅទីបំផុតអតីតមេដឹកនាំខ្មែរក្រហមសំខាន់ៗមួយចំនួននឹងប្រឈមមុខនឹងការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដែលជាផ្នែកមួយរបស់ខ្លួនក្នុងការបង្កើតឲ្យមានសង្គមកសិកម្មឥតវណ្ណៈក្នុងអំឡុងរបបប៉ុលពតពីឆ្នាំ១៩៧៥ - ១៩៧៩ ។ ទោះបីជាភស្តុតាងដែលឧបត្ថម្ភដោយសាធារណៈសម្រាប់បង្កើតសាលាក្តីខ្មែរក្រហម អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនទំនងជាអាចបំពេញបានគ្រប់ការរំពឹងគិតទុករបស់ប្រជាជនកម្ពុជាឡើយ ។ តាមការស្រាវជ្រាវរបស់ខ្ញុំនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៩៩ ខ្ញុំទាញសេចក្តីសន្និដ្ឋានថា ប្រជាជនកម្ពុជាត្រូវការដឹងនូវអ្វីដែលបានកើតឡើងក្នុងរបបប៉ុលពត និងហេតុអ្វីបានរបបនេះកើតឡើង ហើយប្រជាជនកម្ពុជាត្រូវការការទទួលស្គាល់ពីអតីតមេដឹកនាំខ្មែរក្រហមនូវអ្វីដែលពួកគេបានធ្វើខុស ។ ១០ឆ្នាំក្រោយមក សេចក្តីត្រូវការទាំងនេះនៅតែមិនទាន់បានបំពេញ ។ ខណៈដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចផ្តល់យុត្តិធម៌ខ្លះនៅក្នុងទម្រង់ការទទួលស្គាល់ជាអន្តរជាតិ និងការដាក់ទណ្ឌកម្មចំពោះជនដែលដែលប្រសើរជាងគ្មានការផ្តល់ឲ្យនូវយុត្តិធម៌សោះ ទំនងជាអាចឆ្លើយទៅនឹងសំណួរសំខាន់បំផុតថាហេតុអ្វីបានជារបបប្រល័យពូជសាសន៍បានកើតឡើង ប្អូទំនងជាជំរុញឲ្យមានការទទួលស្គាល់នូវកំហុសដែលស្វះស្វែងរកដោយអ្នករស់រានមានជីវិតជាច្រើន ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានកម្រិតព្រំដែនខាងសមត្ថភាពរបស់ខ្លួនដើម្បីបំពេញឲ្យបានពេញលេញនូវសេចក្តីត្រូវការចំពោះយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជានិងសហគមន៍អន្តរជាតិ ។ ខណៈពេលដែលយុត្តិធម៌គឺជាគោលដៅសំខាន់ យុត្តិធម៌តាមផ្លូវតុលាការដោយគ្មានការពិតនិងការទទួលស្គាល់ គឺគ្រាន់តែជាយុត្តិធម៌មិនពេញលេញ ហើយមិនទំនងជាបញ្ចប់នូវវប្បធម៌និទណ្ឌភាពដែលរាលដាលនៅក្នុងសង្គមកម្ពុជាឡើយ ។ ការសិក្សាស្រាវស្រាវបន្ថែមទៀតត្រូវការចាំបាច់ដើម្បីស្វែងរកសក្តានុពលនៃប្រភេទមួយចំនួនអំពីដំណើរការយុត្តិធម៌ស្តារឡើងវិញ ដែលស្ថាបនាទំនាក់ទំនង

ពង្រឹងអត្តសញ្ញាណខ្មែរ និងជំរុញឲ្យមានសន្តិភាពចេរភាពដែលរួមមានយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា ។

**«ចប់»**

ប្រែសម្រួលជាភាសាខ្មែរដោយ សូ ហ្វារីណា
ថ្ងៃទី១១ ខែមករា ឆ្នាំ២០០៩